ការសំភាសន៍របស់បងប្រុស យឿន សារ៉ាត

ក៖ អ្នកដែរសំភាសន៍គេ ជាងស៊ីអ៊ារ ខ៖ អ្នកដែរអោយគេសំភាសន៍យឿន សារ៉ាត

ការសង្ខេបប្រវត្តិរបស់បងប្រុស យឿន សារ៉ាត

បងប្រុស យឿន សារ៉ាត មានអាយុ។បងប្រុស យឿន សារ៉ាត មានភេទប្រុស
បងប្រុស យឿន សារ៉ាត មានទីលំនៅបច្ចុប្បន្ននៅភូមិ។

ក៖
ចឹងជាដំបូងខ្ញុំសូមអរគុណច្រើនបងដែរបានអោយខ្ញុំសំភាសន៍ពីប្រវត្តិរបស់បង
ហើយការសំភាសន៍
នេះត្រូវបានរៀបចំឡើងដោយសកលវិទ្យាល័យមួយដែរនៅអាមេរិចដែរមានឈ្មោះ
ថាBYU
ហើយដោយសារតែសកលវិទ្យាល័យមានគោលបំណងចង់រក្សាពីប្រវត្តិប្រជាជនខ្មែរ
ដើម្បីទុកអោយកូនចៅ
ជំនាន់ក្រោយៗពួកគាត់បានស្គាល់ពីប្រវត្តិរបស់ឪពុកម្តាយ នឹងប្រវត្តិរបស់ដូចគា
ចឹងនៅពេលដែរខ្ញុំបាន
សំភាសន៍បងហើយខ្ញុំនឹងដាក់ការសំភាសន៍មួយនេះទៅក្នុងវេបសាយរបស់សាលា
ដែរមានឈ្មោះថា www.cambodianoralhistories.byu.edu ចឹងហាសបង
ចឹងតើបងយល់ព្រមដើម្បីអោយខ្ញុំដាក់ការសំភាសន៍
មួយនេះទៅក្នុងវេបសាយរបស់សាលាដែរទេបង?
ខ៖ ដាក់ៗៗទៅបង
ក៖ ចឹងសំរាប់ខ្ញុំជាអ្នកដែរសំភាសន៍បងខ្ញុំមានឈ្មោះថា ជាង ស៊ីអ៊ារ
ហើយថ្ងៃខែដែរខ្ញុំសំភាសន៍មួយនេះត្រូវបាន ធ្វើឡើងនៅថ្ងៃទី23 ខែ2 ឆ្នាំ2018
ហើយការសំភាសន៍មួយនេះគឺធ្វើនៅភូមិដក់ពារ ឃុំវល្លិ៍សរ ស្រុកសំរោងទង
ខេត្តកំពង់ស្ពឺ ចឹងសំរាប់បងមានឈ្មោះពេញឈ្មោះអីគេដែរបង?
ខ៖ ឈ្មោះយឿន រ៉ាត
ក៖ ឈ្មោះយឿន រ៉ាត មានឈ្មោះហៅក្រៅទេបង?
ខ៖ អត់ទេគេហៅតែយឿន រ៉ាតៗៗនឹងតែម្តងនឹង
ក៖
ចុះកាលពីក្មេងនឹងធ្លាប់មាននរណាហៅឈ្មោះបងអីផ្សេងពីនឹងទៀតដែរទេបង?
ខ៖ អត់មានដែរមាននរណាគេហៅទេ
ក៖ ចុះបងគិតថាបងសព្វថ្ងៃនឹងបងអាយុប៉ុន្មានដែរបង?
ខ៖ ខ្ញុំអាយុចូល35ឆ្នាំហើយនឹង
ក៖ ចូ35ឆ្នាំឆ្នាំហោសបង
ចុះលក្ខណៈថាឆ្នាំច័ន្ទគតិបងឆ្នាំអីគេដែរបងលក្ខណៈថាឆ្នាំជូត ឆ្លូវ ខាល
ថោះហាសបង?
ខ៖ ខ្ញុំឆ្នាំជូតនឹង
ក៖ ចុះបងនៅថ្ងៃខែឆ្នាំកំណើតរបស់បងនឹងបងកើតនៅថ្ងៃខែឆ្នាំណាដែរបង?
ខ៖ កើតនៅថ្ងៃទី8 ខែ8 ឆ្នាំ1984
ក៖ បងឆ្នាំ1984ប៉ុន្តែបងចូលក្បាលអាយុ35ឆ្នាំហិបង?
ខ៖ បាទៗៗចូល35ឆ្នាំហើយនឹង
ក៖ បាទបងចុះទីកន្លែងកំណើតរបស់បងនឹងបងកើតនៅណាដែរបង?
ខ៖ នៅភូមិព្រែកកន្ទាច
ក៖ នៅឃុំអីគេដែរបង?
ខ៖ នៅឃុំសព៌ណទេព
ក៖ ស្រុកអីគេដែរបង?
ខ៖ នៅស្រុកសព៌ណទេព ឃុំសព៌ណទេព ខេត្តកំពង់ស្ពឺនឹងដែរ
ក៖ ចុះបងមានបងប្អូនចំនួនប៉ុន្មាននាក់ដែរបង?
ខ៖ ខ្ញុំមានបងប្អូនចំនួន6នាក់
ក៖ ចុះបងជាកូនទីប៉ុន្មានដែរទៅ?
ខ៖ ខ្ញុំជាកូនទី3នឹង

ក៖ ចុះមានស្រីប៉ុន្មាននឹងប្រុសប៉ុន្មានដែរទៅបង?
ខ៖ មានស្រី2នាក់ នឹងប្រុស4នាក់
ក៖ ប៉ុន្តែបងប្អូនរបស់បងសព្វថ្ងៃនឹងពួកគាត់រស់នៅនឹងទាំងអស់គ្នា?
ខ៖ នឹងហើយរស់នៅនឹងទាំងអស់គ្នានឹង
ក៖
ចុះបងអាចប្រាប់ឈ្មោះបងប្អូនរបស់បងថាពួកគាត់មានឈ្មោះអីគេដែរបានទេបង?
ខ៖ បងប្រុសនឹងឈ្មោះរុណ ហើយបងស្រីមួយទៀតនឹងឈ្មោះរ៉ុម ហើយខ្ញុំឈ្មោះវ៉ាត ហើយប្អូនមួយទៀត នឹងឈ្មោះវណ្ណី ហើយប្អូនមួយទៀតឈ្មោះតាក់ ហើយប្អូនមួយទៀតនឹងឈ្មោះសុខា
ក៖ ចុះបងមានចងចាំអនុស្សាវរីយ៍អីកាលពីបងនៅក្មេងៗៗអាយុ4-10ឆ្នាំអីចឹងធ្លាប់លេងអីគេជាមួយពួក គាត់ដែរដូចជាលេងឡឺកជាយឡរីមួយក៏លេងបិទពួនលេងស្អីៗចឹងហាសបងធ្លាប់លេងអីជាមួយពួកគាត់ ដែរទេបង?
ខ៖
អត់សូវដែរបានលេងទេបងអើយកាលណុងយើងវាក្មេងហើយម៉ែឪរៀងអត់ទៀតចឹងយើងមិនសូវ បានដើរលេងទៅណាទេចឹងហាស
ក៖ បានបងបានចឹង?
ខ៖ ដូចថាម៉ែឪចេញបាត់ៗៗចឹងហាសហើយយើងនៅផ្ទះចឹងជួនកាលពីរើសអូសរើសអាចម៏គោអីចឹង ចឹងទៅណាស់រើសយកមកដុតដាំបាយ
ឡើងស្មោគនឹងដុតស្មោគចឹងហាស
ក៖ បានបងនឹងហោស?
ខ៖
ចឹងថាជីវិតរបស់ក្រវាក់សត់ដែរនឹងហាសវាមិនសូវបានរៀនសូត្រអីប៉ុន្មានដែរទេនឹង
ក៖ អ៎!បានចឹងបង?
ខ៖ រៀនបានថ្នាក់ទី6ថ្នាក់ទី7អីនឹងហាស
ក៖ ចុះកាលពីនៅក្មេងៗៗនឹងបងចូលចិត្តលេងអីគេជាមួយបងប្អូនរបស់បងមិញដូចជាបងធ្លាប់លេង
ប៉ុន្តែនេះដូចជាបងចូលចិត្តលេងអីជាមួយពួកគាត់ដែរបង?
ខ៖ គ្មានលេងអីទេមិនដែរបានលេងអីទេ
គ្រាន់តែថាបងប្អូននឹងលេងសើចៗៗតែពេលល្ងាចឡើងនឹងយប់ឡើងអីទេដូចថាពេលម៉ោងដេកអីនឹងប្រលែងគ្នាតែប៉ុណ្ណឹងទេនឹងប្រលែងគ្នានឹង
ក៖ អ៎!បានបងចុះបងចូលចិត្តធ្វើអីគេជាមួយពួកគាត់ដែរបង?
ខ៖
អត់សូវបានធ្វើអីទេគ្រាន់តែព្រលឹមឡើងហូបបាយហូបអីចឹងខ្លះទៅរៀនចឹងទៅខ្លះទៅរើសអូស ខ្លះទៅច្រូតស្មៅគោចឹង
ក៖ អ៎!បានចឹងបង?
ខ៖ ថ្ងៃត្រង់យើងចូលមកវិញនឹងយើងហូបបាយហូបអីចឹងទៅ
ក៖ បានចឹងបង?
ខ៖ ខ្លះគាត់ដេកអង្រឹង
ខ្លះដេកលើត្រែអីចឹងទៅពេលដែរដល់ម៉ោងចឹងយើងទៅមើលគោនឹងដឹកគោចង អីចឹងហាសបង
ក៖ ចុះបងគិតថាបងប្អូនរបស់បងសព្វថ្ងៃនឹងពួកគាត់នៅណាខ្លះដែរទៅបង?
ខ៖ នៅភូមិព្រែកកន្ទាចនឹង
ក៖ នៅភូមិព្រែកកន្ទាចនឹងនៅឆ្ងាយពីភូមិនឹងមែនទេបង?
ខ៖ រំលងភូមិប្រហែលជា3ភូមិអីនឹងនោះជាប្តូរទៅចំបកនឹងទៅចឹង
ក៖ ប៉ុន្តែពួកគាត់ទៅនៅនឹងទាំងអស់គ្នារីយ៉ាងណាដែរបង?
ខ៖ មានគ្រួសារមួយទៅនៅជិតត្រពាំងក្រឡឹងនៅម្ដុំត្រពាំងក្រឡឹង
ក៖ បានបងបានចឹង?

ខ៖ ហើយក្រៅពីនឹងមានគ្រួសារនៅក្នុងភូមិនឹង
ហើយមួយទៀតមានគ្រួសារនៅខេត្តសៀមរាបប៉ុន្តែគេ យកមកនៅនេះ
ក៖ អ៎!បានប៉ុន្តែមានតែបងមួយទេដែរនៅនឹង?
ខ៖ បានមានតែខ្ញុំមួយទេ
ក៖ បងមកខាងប្រពន្ធរបស់បងមែនទេបង?
ខ៖ ខ្ញុំមកខាងប្រពន្ធនឹង
ក៖ ចុះដូចជាបងប្អូនរបស់បងនឹងសព្វថ្ងៃពួកគាត់ធ្វើអីគេខ្លះដែរទៅបង?
ខ៖ បងមួយគាត់ទៅធ្វើការនៅភ្នំពេញហោស
ហើយបើអាប្អូនៗៗពីរនាក់ទៀតនឹងទៅធ្វើការនៅរោងចក្រ
ក៖ ស្រីៗនឹងហោសបង?
ខ៖ អត់ទេប្រុសពីរនាក់នឹងធ្វើការនៅរោងចក្រដែរ
ហើយមានស្រីមួយក៏ធ្វើការនៅរោងចក្រដែរនឹង
ក៖ អ៎!បានប៉ុន្តែពួកគាត់មានគ្រួសារអស់នៅបង?
ខ៖ មានគ្រួសារអស់ហើយនឹងនៅសល់មួយ
ក៖ នៅសល់ប្អូនពៅនឹងហោសបង?
ខ៖
អត់ទេនៅសល់បងគេនឹងនៅសល់បងបន្ទាប់ខ្ញុំនឹងដូចថាគាត់មិនសូវដឹងអីហា
ស គាត់នៅតែផ្ទះដាំ បាយអត់ធ្វើការអីកើតហាស
ក៖ អ៎!ប៉ុន្តែចង់និយាយថាគាត់ដឹងទាំងអស់តើហីបង?
ខ៖ គាត់ដឹងទាំងអស់នឹងប៉ុន្តែគ្រាន់តែថាគាត់ទៅធ្វើការអីអត់កើតទេនឹង
ដូចថាគាត់ធ្វើការតមាត់ដូចថា គាត់ចង់ធ្វើៗៗទៅ
បើគាត់មិនចង់ធ្វើវិញដើរចេញបាត់នឹង
ក៖ អ៎!គាត់ចឹងហោសបង?
ខ៖ ដូចថាគាត់ពិបាកចឹងហាសប៉ុន្តែនៅផ្ទះធម្មតាដាំបាយ ស្ល
ក៖ និយាយទៅពិបាកយល់ចរិកគាត់ណាបង?
ខ៖ បានគាត់ពិបាកយល់
ក៖ គាត់ស្រីរឺមួយក៏ប្រុសបង?
ខ៖ គាត់ស្រី
ក៖ ប៉ុន្តែគាត់អាយុប៉ុន្មានដែរបងដល់ឥឡូវនឹងហាស?
ខ៖ បងខ្ញុំទៀតនឹងគាត់ប្រហែលជាអាយុ38ឆ្នាំអីនឹង
ក៖ អ៎!ប៉ុន្តែឥឡូវនឹងគាត់នៅណាដែរទៅបង
គាត់នៅជាមួយនរណាគេដែរទៅបង?
ខ៖ នៅជាមួយពុកនឹងនៅជាមួយប្អូនពៅមួយដែរនឹង
ក៖ អ៎!បានបង ចុះឪពុករបស់បងគាត់មានឈ្មោះអីគេដែរបង?
ខ៖ គាត់មានឈ្មោះយឿន
ក៖ គាត់ឈ្មោះស្នឹគេយឿនទៅបង?
ខ៖ ឈ្មោះខៀវ យឿន
ក៖ ចុះគាត់សព្វថ្ងៃគាត់អាយុប៉ុន្មានដែរបងមានដឹងទេ?
ខ៖ គាត់ចូលហាជាងហើយបងអើយ
ក៖ ហាប៉ុន្មានដែរបងមានដឹងទេ?
ខ៖
អត់ដឹងច្បាស់ដែរប៉ុន្តែចូលហាហើយនឹងត្រឹមខ្ទង់ហានឹងមិនដល់ហាហុកទេនឹង
ខ្ទង់ហាជាងនឹង 53ឆ្នាំរឺ54ឆ្នាំអីនឹងគាត់ចាស់ដែរ
ក៖ បានបង ចុះគាត់កើតនៅថ្ងៃខែឆ្នាំណាបងមានដឹងទេ?
ខ៖ ប្អូនមិនដឹងទេបងអើយ
ក៖ សូម្បីតែឆ្នាំគាត់ក៏បងមិនដឹងដែរណាបង?
ខ៖ បានៗៗនឹងហើយ
ក៖ បានចុះឪពុករបស់បងគាត់កើតនៅណាដែរបងមានដឹងទេ?
ខ៖ គាត់កើតនៅស្លកកន្ទាលនៅខាងក្បែងនឹងបន្តិចនឹង
ក៖ នៅស្រុក.....?
ខ៖ នៅស្រុកណុងដែរនឹងជាមួយគ្នានឹងនៅស្រុកសំព៉ាណទេពនឹង

ក៖ នៅស្រុកសំព៌ណទេព ចុះម្តាយរបស់បងគាត់មានឈ្មោះអីគែដែរបង?
ខ៖ គាត់មានឈ្មោះឡឹង រឿន
ក៖ គាត់ឈ្មោះឡឹង រឿន
ដល់ឥឡូវនឹងគាត់ប្រហែលជាអាយុប៉ុន្មានដែរបងមានចងចាំទេ?
ខ៖ គាត់ប្រហែលជាសែសិបហាថហាចុះនឹងហាសគាត់ស្លាប់បាត់ហើយនឹង
ក៖ អូ!គាត់ស្លាប់ចឹងមានន័យថាបងសព្វថ្ងៃនឹងនៅសល់តែឪពុកទេ?
ខ៖ បាទនៅតែឪពុកនឹង
ក៖ ចុះម្តាយរបស់បងគាត់កើតនៅណាដែរបងមានចងចាំទេ?
ខ៖ គាត់កើតនៅក្នុងភូមិព្រែកកន្ទាចនឹងតែម្តង
ក៖ បាទបង ចុះឪពុករបស់បងកាលពីគាត់មិនទាន់បានម្តាយរបស់បង
នឹងគាត់បានម្តាយរបស់បងនឹង
តើគាត់ធ្វើអីគែដែរសំរាប់ចិញ្ចឹមក្រុមគ្រួសារដែរបង?
ខ៖ គាត់ប្រវត្តិរបស់គាត់នឹងតស៊ូដែរនឹងរកស៊ីលក់ដូរការ៉ែ បញ្ចូលដែកកះ
គាត់ឡើងភ្នោតអូគាត់ហត់
ណាស់បងអើយទំរាំបានកូនប៉ុណ្ណឹងគាត់ការងារអីក៏គាត់ធ្វើដែរនឹង
ក៖ ប៉ុន្តែប្រពន្ធរបស់គាត់បានស្លាប់នៅពេលណាដែរទៅបង?
ខ៖ ប្រពន្ធរបស់គាត់ទើបតែស្លាប់បានប្រហែលជា3-4ខែនឹងទេបង
ក៖ អូ!ចឹងទើបតែស្លាប់ថ្មីៗៗនឹងហោសបង?
ខ៖ បាទទើបតែស្លាប់ថ្មីៗៗនឹងទេ
ក៖ ចុះឪពុករបស់បងគាត់កាចរឹមក៏ស្លូតដែរបង?
ខ៖ គាត់កាច
កាចចំពោះអ្នកដែរខូចដែរនឹងដូចខ្លុំអីចឹងណាស់គាត់កាចចុះដូចជាទៅច្រូតស្មៅ
គោមួយ កន្ទេលមួយជាលអីចឹងទៅដើរជាត់ទល់ល្ងាចបានចូល
ក៖ អូ!ចឹងបង?
ខ៖ ដល់ពេលព្រលប់ៗៗចូលមកកាយគាត់ខឹងណាស់
ក៖ គាត់ខឹងណាបងប៉ុន្តែគាត់វែទេបង?
ខ៖
គាត់វែធម្មតារំពាត់ឡើងលើផ្ទះចឹងបិទទ្វាជិតបទជើងៗវែរៀងនៅអូបងអើយ
ក៖ អូ!ប៉ុន្តែកាលណុងបងនៅក្មេងៗណាបង?
ខ៖ នៅក្មេងៗៗនឹងហាស
ក៖ អូ!បាទបង
ចុះកាលម្តាយរបស់បងគាត់នៅរស់គាត់ធ្វើអីគែដែរសំរាប់ចិញ្ចឹមជីវិតដែរបង?
ខ៖ គាត់នៅផ្ទះធ្វើស្រែកសិកររនឹងហាស គាត់ធ្វើស្រែធ្វើចំការនឹងហាសបង
ក៖ អូ!បាទបងចុះគាត់ជាមនុស្សបែបណាដែរបងគាត់ស្លូត រឺមួយក៏កាចដែរបង?
ខ៖ ម្តាយរបស់ខ្លុំគាត់ស្លូតនឹងអត់ចេះកាចទេធម្មតានឹងស្លូតនឹងញឹមៗៗនឹង
ក៖ បាទបងចុះបងមានចងចាំសាច់រឿង
ដូចជាអនុស្សាវរីយ៍អីជាមួយឪពុកម្តាយរបស់បងកាលពីបងនៅ
ជាមួយគាត់ពេលដែរបងមិនទាន់មានគ្រួសារហាស
បងធ្លាប់ធ្វើអីគេខ្លះជាមួយគាត់?
ខ៖
ធ្លាប់អីបងគ្រាន់តែធ្លាប់ហូបបាយថ្ងៃត្រង់ចឹងជួបជុំគ្នារកចៃអោយកូនចឹងទៅ
ក៖ អូ!ចឹងបង?
ខ៖ គាររកចៃអោយកូនពេលយប់ឡើងប្រលែងគ្នាចឹងទៅ
ម៉ែឪថ្ងៃសប្បាយចិត្តទៅប្រលែងគ្នាទៅ ថ្ងៃណាមិនសប្បាយចិត្តរៀងខ្លួនចឹងទៅ
ក៖ មិនមុខគ្នាមិនចង់មចឹងទៅ?
ខ៖ នឹងហើយវាចឹង
ក៖
ចុះបងគិតថាធ្លាប់ទៅស្រែរឹមួយក៏ធ្វើអីមួយដែរធ្វើអោយបងចងចាំជាមួយពួក
គាត់ដែរទេ?
ខ៖ ចាំបំផុតនឹងទៅស្រែនាំគ្នាស្លូង ដកហើយនាំគ្នាហូបបាយក្រោមដើមឈើហាស
ក៖ ជាមួយឪពុកម្តាយចឹង?

ខ៖ បាទនឹង
ក៖ នឹងជាមួយបងប្អូនរបស់បងទាំងអស់គ្នាចឹងទៅ?
ខ៖ បាទនៅជុំគ្នាចឹងទៅ
ក៖
ចុះឪពុករបស់បងគាត់មានធ្លាប់ប្រាប់ពីប្រវត្តិរបស់គាត់កាលពីគាត់នៅក្មេងៗទៅបងទេ?
ខ៖ អត់ដែរប្រាប់ផងគាត់ប្រាប់តើពេលដែរគាត់ទៅធ្វើកប្រាំ
គាត់ប្រាប់តែមួយម៉ាត់ពីរម៉ាត់ដែរនឹងយើងថាំ
មិនអស់ដែរនឹងគាត់ទៅធ្វើកប្រាំគាត់ថា
ក៖ នឹងជំនាន់ពលពតហោសបង?
ខ៖ នឹងជំនាន់ពលពតនឹងចុះយើងអត់ស្គាល់ហើយនឹងកើតមិនទាន់ហោស
ក៖ បាទបងបាទ?
ខ៖
គាត់ថាហែងសំណាងហើយដែរកើតមិនទាន់ពលពតហោសគ្រាន់តែកប្រាំនឹងអញ្ជរត់ចោលផ្ទះឡើង ប៉ុន្តានថ្ងៃដែរនឹងខ្លាចគេចាប់យកទៅធ្វើជាទាហ៊ាន
ក៖ ហាសកាលពីជំនាន់ពលពតនឹងគេតំរូវអោយគាត់ធ្វើមែនទេបង?
ខ៖ គេតំរូវអោយគាត់ធ្វើប៉ុន្តែអ្នកខ្លះនឹងគេអោយធ្វើប៉ុន្តែមិនធ្វើរត់ចោលខ្លាចចាប់យកទៅធ្វើជាទាហ៊ាន នឹងណាស់
ក៖
ប៉ុន្តែគេរត់ទៅណាបើនៅស្រុកខ្មែរគេពោពេញទៅដោយពលពតអស់ហើយនឹងបង?
ខ៖ គេចូលព្រៃចឹងហាសគាត់ថាដែរនឹងខ្ចុំមិនសូវដឹងដែរនឹង
ក៖
ចុះគាត់មានដែរប្រាប់ខ្លះទេបងថាកាលពីជំនាន់ពលពតគេអោយគាត់ធ្វើអីគេខ្លះ ហើយអោយគាត់ នៅណាអីចឹង?
ខ៖ គាត់មិនដែរប្រាប់ទេបង
ប៉ុន្តែបើម៉ែគាត់ប្រាប់ថាពីមុនគាត់នៅជំនាន់ពលពតនឹងគាត់នៅកងកុមារ
គាត់ថាគេអោយនៅតែដាំបាយនឹងវាស់អង្ករអោយគេទេនឹង
ក៖ អ៊ូ! ចុះពេលណុងគាត់មានដែរប្រាប់ថាគាត់នៅណាទេបង
គេជំលាសគាត់ទៅណាដែរចឹងហាស?
ខ៖ កាលណុងគាត់ថានៅម្ពុំជើងហោសនៅក្រាំងចេក
ក៖ អ៊ូ!នៅក្រាំងចេកហោសបង ចុះពេលណុងគាត់មិនទាន់មានគ្រួសារទេណបង
គាត់មិនទាន់បានការ ជាមួយគ្នាទេណបង?
ខ៖ បាទមិនទាន់ទេនឹងមិនទាន់មានគ្រួសារទេ
ក៖ ចុះបងមានដឹងថាគាត់ស្គាល់គ្នាដោយរបៀបណាដែរបងមានដឹងទេបង?
ខ៖ គាត់ថាកងគេចាប់ចូលគ្នាអោយយកៗៗចឹងតែម្តងនឹងបង
ក៖ អ៊ូ!លក្ខណៈថាគេចាប់អោយ?
ខ៖ អោយការចឹងទៅនឹង
ក៖ លក្ខណៈថាគេចាប់មកជ្រើនគូរហើយយកមកការចឹងហោសបង?
ខ៖ នឹងហើយវាចឹងបងជំនាន់មុនតែចឹង
ក៖ ទោះយើងមិនស្រលាញ់គ្នាក៏ត្រូវតែទៅដែរនឹង?
ខ៖ នឹងហើយ
ក៖ អ៊ូ!នេះជាប្រវត្តិម្តាយរបស់បងកាលនៅពីក្មេង?
ខ៖ បាទៗនឹងហើយ
ក៖ ចុះយាយតាខាងឪពុកបងមានស្គាល់ឈ្មោះគាត់ដែរទេបង?
ខ៖ យាយតាខាងឪពុកខ្ចុំអត់ស្គាល់ទេខាងឪពុកស្គាល់តែតាឈ្មោះខៀវនឹង
ក៖ ឈ្មោះតាខៀវ?
ខ៖ បាទនឹងហើយចឹង
ក៖ ចុះតាគាត់កើតនៅណាដែរបងអត់?
ខ៖ នៅស្រុកកន្ទាលនឹងដែរនឹង
ក៖ ប៉ុន្តែយាយបងឯងមិនដឹងថាគាត់កើតនៅណាទេ?

ខ៖ អត់ដឹងថាគាត់នៅណាទេ
ក៖ ចុះយាយតាខាងម្តាយហោសបង?
ខ៖ យាយតាខាងម្តាយនៅភូមិព្រែកទទាចនឹងតែម្តងនឹង
ក៖ ទាំងយាយទាំងតានឹងហោសបង?
ខ៖ ទាំងយាយទាំងតានឹង
ក៖ ចុះគាត់មានឈ្មោះអីគេដែរបងមានដឹងទេ?
ខ៖ គាត់ឈ្មោះគល់ ឡឹង នឹងឈ្មោះទឹម
ក៖ គល់ឡឹងយាយហ៊ីបង?
ខ៖ ឡឹងនឹងឈ្មោះតា ឈ្មោះទឹមនឹងយាយ
ក៖ អ៊ូ!បានបងចុះបងមករស់នៅនឹងយូរនៅបង?
ខ៖ ប្រហែលជា8ឆ្នាំហើយនឹង
ក៖ អស់រយៈពេលពេល8ឆ្នាំ?
ខ៖ វាយូរដែរហើយនឹង
ក៖ ចុះបងមានបងប្អូនរឺមួយក៏កូនក្មួយណាដែរគាត់រស់នៅក្រៅប្រទេសទេបង?
ខ៖
មានអ៊ុំប៉ុន្តែគ្រាន់តែនៅណាឆ្ងាយណាស់មិនដឹងនៅណាទេប៉ុន្តែឥឡូវនឹងគាត់មកនៅស្រុកខ្មែរដែរនឹង ហាស
ក៖ អ៊ូ!ចុះពីមុនគាត់នៅណាបងឯងមានដឹងទេ?
ខ៖ គាត់នៅកាណាដាហោស
ក៖ អ៊ូ!គាត់នៅកាណាដា?
ខ៖ បាទនឹង
ក៖ ចុះភរិយារបស់បងមានឈ្មោះអីគេដែរទៅបង?
ខ៖ ឈ្មោះភាព
ក៖ ចុះឈ្មោះស្អីគេភាពដែរបង?
ខ៖ ឈ្មោះធារ៉ា ភាព
ក៖ អ៊ូ!ឈ្មោះធារ៉ា ភាពណបង
ចុះបងមានចងចាំថ្ងៃខែដែរបងរៀបអាពាហ៍ជាមួយគាត់ដែរទេបង?
ខ៖ អត់ចាំទេ
ក៖ អ៊ូ!អត់ចាំទេណបង?
ខ៖ អត់ចាំទេទាល់តែមើលរូបថតបានដឹងនឹង
ក៖ ប៉ុន្តែកូនរបស់បងដែរបងគេនឹងគាត់អាយុប៉ុន្មានដែរបង?
ខ៖ អាយុ10ឆ្នាំនឹង
ក៖ អាយុ10ឆ្នាំហើយ ចុះបងពេលដែរការនឹងបងមានកូនភ្លាមរឺក៏បងចាំសិន?
ខ៖ ពេលការភ្លាមនឹងមានកូនភ្លាម
ក៖ ចឹងមានន័យថាបងការតាំងពីអាយុអស់ជា11ឆ្នាំហើយចឹងហោសបង?
ខ៖ បាទនឹងហើយ
ក៖ ប្រហែលជាបងអាយុ24ឆ្នាំនឹង?
ខ៖ នឹងៗៗហើយប្រហែលខ្ទង់ខ្ទុំអាយុ24ឆ្នាំនឹង
ក៖ ចឹងសំរាប់នៅពេលដែរបងរៀបអាពាហ៍ពិពាហ៍ជាមួយប្រពន្ធរបស់បងនឹងដូចជាបងចង់រៀបចំដោយ
ចិត្តឯងរឺក៏ឪពុកជាអ្នកចង់រៀបចំអោយយើងដែរបង?
ខ៖ ឪពុកម្តាយបង
ចុះខ្ញុំពេលណុងដូចថាមិនទាន់ចង់ចេះស្រលាញ់អីទេតែម៉ែឪទេចាប់ទៅណាទៅណុង យើងចេះតែតាមម៉ែឪទៅ
ក៖ អ៊ូ!ពេលណុងគាត់ចង់អោយបងយកប្រពន្ធហោសបង?
ខ៖ បាទៗៗនឹងហើយចឹង
ក៖ ប៉ុន្តែពេលណុងបងធ្វើអីគេដែរទៅបង?
ខ៖ ខ្ញុំដើរធ្វើជាម្ហូបចុងភៅគេនឹងនៅតាមរោងការគេអីនឹង
ក៖ ប៉ុន្តែឥឡូវនឹងបងឈប់ហើយណបង?
ខ៖ ខ្ញុំឈប់ហើយដូចថាមិនសូវបានមកផ្ទះនឹងថាមួយខែអីចឹងទៅបាត់ៗៗ
ក៖ ប៉ុន្តែយើងធ្វើបានប្រាក់ខែច្រើនដែរតើហ៊ីបង?

ខ៖
ប្រាក់ខែការណុងយើងធ្វើបានមួយរោងៗៗចឹងយើងបានតិចដែរនឹងគេគិតតែមួយរោងចឹងទៅ គេគិតតែតាមម្ហូបមួយរោងចឹងទៅបានតែ3ម៉ឺន
ទៅ4ម៉ឺនទេនឹង
ក៖ អ៎!តិចដែរ?
ខ៖ បាន3-4ម៉ឺននឹង3-4ថ្ងៃអីហោស
ក៖ ប៉ុន្តែណុងមិនមែនយើងមេចុងភៅណាហ៊ីបង?
ខ៖ មិនមែនមេទេយើងជាកូនកាំបិតនឹងហាស
ក៖ យើងជាកូនកាំបិតគេធម្មតាទេណបង?
ខ៖ បាទៗៗនឹងហើយ
ក៖ ហើយគេជួលយើងទៅធម្មតាចឹងទៅ?
ខ៖ បាទគេជួលយើងធម្មតាចឹងទៅណាស់
ក៖ អ៎!3-4រោងបាន10$?
ខ៖ មិនមែនទេ3-4ថ្ងៃដូចថាមួយរោងនឹងចាប់ពីថ្ងៃយើងចូលរោងចឹងទៅ
ដល់ថ្ងៃគេហូបហើយដល់ល្ងាច ទៀតហោសដូចជា3ថ្ងៃទៅ4ថ្ងៃហោស
ក៖ ចឹងបានតែ10$ទេហោសបង?
ខ៖ ពីមុននឹងលុយវាថោកដែរបានតែ10$នឹង
ប៉ុន្តែឥឡូវនឹងខ្ញុំសួរគេឥឡូវនឹងកូនកាំបិតនឹងមួយរោងបាន10ម៉ឺនដែរនឹង
ក៖ បាទខ្ជិលថាបាន25$ -30$បង?
ខ៖ បាននឹងហើយប៉ុណ្ណឹងកាលណុងវាថោកដែរនឹង
ក៖
គិតថាពេលដែរបងចូលស្តីដណ្តឹងបងស្រីនឹងបងមានជំនួនជូនទៅគាត់ដែរទេបង?
ខ៖ មានដែរតើបង!
ក៖ ដូចជាមានប៉ុន្មានដែរបងអាចខ្ជំបានទេបង?
ខ៖ អោយទៅ2000ពាន់
ក៖ អ៎!អោយទៅបាន2000ហោសបង?
ខ៖ បាននឹងហើយ
ក៖ ចុះបងខ្ញុំអាចសុំសួរមួយដែរទាក់ទងពីប្រវត្តិរបស់បង
ដូចជាបងស្រលាញ់ប្រពន្ធរបស់បងនៅពេល
ណាហើយហេតុអីបានជាបងស្រលាញ់គ្នាហើយរយៈពេលប៉ុន្មានដែរបងបានចូលស្តីដណ្តឹងគាត់អីចឹង ហាសបង?
ខ៖ កាលណុងម៉ែឪនាំមកមកមើលនិយាយទៅតាមតែម៉ែឪនឹងបង
យើងអត់ដឹងដែរគ្រាន់តែតាមម៉ែឪនឹង
គាត់ថាយកម្នាក់នឹងក៏យកម្នាក់នឹងតាមគាត់ទៅ
ការហើយធម្មតាការហើយប្តីប្រពន្ធនៅជាមួយគ្នាធម្មតា
នៅជាមួយគ្នាធម្មតាចឹងទៅ
ក៖ អ៎!ចឹងទេ?
ខ៖ អត់មានអីទេបង
ក៖ ប៉ុន្តែខាងស្រីក៏គេយល់ព្រមខាងយើងដែរ?
ខ៖ បាទៗៗនឹង
ក៖ ប៉ុន្តែដូចជាបងចេះអាន រឺមួយក៏ចេះសរសេរអក្សរខ្មែរបានល្អប៉ុណ្ណាដែរ?
ខ៖ មួយជុំមួយធម្មតាអាចមើលបាន
ក៖ ប៉ុន្តែបងរៀនបានថ្នាក់ទីប៉ុន្មានដែរបង?
ខ៖ ខ្ញុំរៀនបានថ្នាក់ទី8បង
ក៖ កាលពីបងរៀននឹងមានន័យថាបងរៀនច្រើនសាលាមែនទេបង?
ខ៖ រៀនបានពីថ្នាក់ពីមួយដល់ថ្នាក់ទី8នឹង
ក៖ ប៉ុន្តែចង់និយាយថាកាលពីថ្នាក់ទីមួយដល់ថ្នាក់ទី6បងរៀននៅបឋមសិក្សា?
ខ៖ បឋមសិក្សាបានបង
ក៖ ប៉ុន្តែបងរៀននៅណាដែរបង?
ខ៖ រៀននៅវិទ្យាល័យបឋមសិក្សាវិទ្យាល័យចំបកនឹង

ក៖ ប៉ុន្តែនៅពេលវិទ្យាល័យនឹងបងរៀននៅនឹងដដែល?
ខ៖ បាទជាប់គ្នារៀនជាប់គ្នានឹង
ក៖
អ៎!បានចុះកាលពីបងរៀននឹងបងធ្លាប់មានមិត្តភក្តិស្និទ្ធីស្នាលជាមួយគ្នាដែរទេបង?
ខ៖ ផ្តាប់មានដែរនឹងបងមានតើ!!
ក៖ ប៉ុន្តែបងអាចប្រាប់ឈ្មោះមួយចំនួនដែរបងចាំបានទេ?
ខ៖ គាត់នៅភូមិនឹងទាំងអស់នឹងហាសមានឈ្មោះវណ្ណី មានឈ្មោះរីម
មានតែពីរបីនាក់នឹង
ក៖
អ៎!បានចុះបងមានចងចាំអនុស្សាវរីយ៍កាលពីបងនៅរៀនរឺមួយក៏ធ្លាប់ទៅស្រែ
រឺមួយក៏ធ្លាប់លេងអី ជាមួយគ្នាចឹងហាស?
ខ៖ មានតែពេលដូចថាចេញពីរៀនមកនឹង
ល្ងាចឡើងចឹងជួនកាលនាំគ្នាទៅហូបអីនៅមុខរោងចក្រចឹង
ទៅណាស់មានតែប៉ុណ្ណឹងបីទៅបួននាក់នឹង
ក៖ អ៎!បានបង?
ខ៖ ពេលវាត្រូវការទៅនោះជួនវាទៅនោះអីវិញអីពួកម៉ាក់មានតែប៉ុណ្ណឹង
ក៖
ប៉ុន្តែបងមានធ្លាប់ទៅស្រែជាមួយគ្នាធ្លាប់ចាប់ត្រីចាប់ក្តាមអីជាមួយគ្នាដែរទេបង?
ខ៖
ធ្លាប់ជួនការនៅម្លិចនឹងថ្ងៃអាទិត្យចឹងទៅមិនជាច់ទៅណាទេនាំគ្នាអូសត្រីគ្នាបីបួននាក់ចឹងទៅណាស់
ក៖ បានបងបាទ?
ខ៖
បានអូសត្រីចឹងទៅនាំគ្នាចែកគ្នាចឹងទៅបានបីចំណែកទៅបួនចំណែកចឹងទៅ
ក៖ ដល់ពេលហើយក៏យកមកជីកជុំគ្នាចឹងទៅ?
ខ៖ អត់ទេបងកាលណុងដូចជាគ្មានទាន់មានអ្នកហូបទេបង
កាលណុងដូចជាគ្មានអីណាហូបទេ
ក៖ អ៎!បានបងបាទ?
ខ៖ ទាល់តែរបៀបទាល់តែជិតមានប្រពន្ធនឹងបានមានគ្មោតជូរ
នៅមុខទីនោះដល់ពេលចឹងនាំគ្នាហៅគ្នា
គ្នាបីតៅបួននាក់ទៅមកជុំគ្នាហូបចឹងទៅ
ក៖
យើងទៅបង់សំណាញ់អីចាប់ត្រីទៅបានមកយើងយកមកធ្វើក្លែមជុំគ្នាហូបទៅ?
ខ៖ បានៗៗនឹងហើយចឹង
ក៖ អ៎!សប្បាយដែរ ចុះបងគិតថាបងមានចេះភាសាអីក្រៅពីភាសាខ្មែរទេបង?
ខ៖ អត់ចេះទេបងយើងចេះតែភាសាខ្មែរនឹងយើងមិនដែលរៀនផងនឹង
ក៖ ចុះបងធ្លាប់ទៅធ្វើស្រែចំការអត់បង?
ខ៖ ផ្តាប់តើ!!!!
ក៖ អ៎!ធ្វើអីគេដែរនៅស្រែចំការហោសបង?
ខ៖ មានដកស្លូង ភ្ជួរអ្នកស្រែនឹងចេះសឹងទាំងអស់នឹងបងព្រុះបាចជី
ក៖ អ៎!ចឹងហោសបង?
ខ៖
ដូចថាអត់អោយទាស់តែម្តងដូចថាគឺចេះតែម្តងនឹងមនុស្សមែនប៉ុន្តែអោយចេះទាំងអស់នឹង
ក៖ បានបងបាទ?
ខ៖ ប៉ុន្តែប្រពន្ធរបស់ខ្ញុំនឹងមិនដែរទៅផងនឹង
ក៖ ចុះបងធ្លាប់បើកអាជីវកម្មលក់ដូរអីទេបង?
ខ៖ អត់ដែរទេបងអើយ
ក៖ ចុះបងមានធ្លាប់ចិញ្ចឹមសត្វទេបងដូចជាចិញ្ចឹមមាន់ គោ ក្របី ជ្រូក?

ខ៖ ធ្លាប់ចិញ្ចឹមដែរនឹងបង?
ក៖ ធ្លាប់ចិញ្ចឹមអីគេដែរបង?
ខ៖ ធ្លាប់ចិញ្ចឹមគោ ចិញ្ចឹមមាន់ ប៉ុន្តែមិនដែរចិញ្ចឹមជ្រូកទេនឹង
ក៖ ប៉ុន្តែបងចិញ្ចឹមលក្ខណៈជាច្រើនរឿយក៏ចដែរបង?
ខ៖ ចិញ្ចឹមលក្ខណៈជាគ្រួសារនឹង និយាយទៅចិញ្ចឹមលក្ខណៈជាគ្រួសារនឹង
ក៖
ចុះបងគិតថាតាំងពីក្មេងរហូតមកដល់ឥឡូវនឹងហាសបងគិតថាបងធ្លាប់ធ្វើការងារអីគេខ្លះដែរបង?
ខ៖ អ៊ូ!ច្រើនមុខណាស់បងធ្វើការនៅរោងចក្រ ទៅយាមផ្ទះសំណាក់ ធ្វើសំណង់ ធ្វើម្ហូប
ក៖ ឥឡូវនឹងបងរត់ព្រូឡាន?
ខ៖ ឥឡូវនឹងរត់ព្រូឡានមានច្រើនណាស់បង?
ក៖
ចុះបងគិតថាជីវិតរបស់បងមានការផ្លាស់ប្តូរអីគេដែរតាំងពីក្មេងរហូតមកដល់ឥឡូវនឹងហាស?
ខ៖ មានការផ្លាស់ប្តូដែរតើបង
កាលពីក្មេងពីមុនជាត់ដៃទទេដល់ពេលដែរឥឡូវនឹងមានផ្ទះមានម៉ូតូមានអីធម្មតានឹង វាមិនក្រហើយក៏មិនអត់ដែរវាធម្មតានឹង
ក៖ បាទបងបាទ?
ខ៖ ដូចតែគេដូចតែឯងដែរនឹង
ក៖ បាទចុះបងចូលចិត្តពិសារម្ហូបអីគេដែរបង?
ខ៖ តែក្រៀមក្រស់នឹង
ក៖ តែក្រៀមក្រស់ទេ ចុះលក្ខណៈស្ងោរ ឆា ការី សូអីបងមិនសូវជាចូលចិត្តទេ?
ខ៖ អត់សូវជាចូលចិត្តទេបង?
ក៖ ភាគច្រើនក្រៀមក្រស់នឹងអីគេដែរបង?
ខ៖ ចៀនសាច់ជ្រូក ត្រីអាំងនឹង
ក៖
អ៊ូ!ចុះកាលបីនៅក្មេងនឹងបងចូលចិត្តលេងល្បែប្រជាប្រិយ៍អីទេបងដូចជាចោលឈូង ទាញព្រាត លាក់កន្សែង ស្មេចចង់ រឺមួយក៏ដណ្តើមស្លឹកឈើអីចឹងហាសបង?
ខ៖ កាលណុងចូលចិត្តលេងដណ្តើមស្លឹកឈើ
ក៖ ដណ្តើមស្លឹកឈើប៉ុន្តែភាគច្រើននឹងបងទៅលេងនៅណាដែរបង?
ខ៖ លេងនៅក្នុងភូមិហើយនឹងនៅមុខរោងចក្រនឹង
ក៖ អ៊ូ!ចឹងហោសបង?
ខ៖ នៅរោងចក្រនៅកន្លែងវត្តចំបកនឹង
ក៖ នៅពេលដែរយើងនៅជិតចូលឆ្នាំខ្មែរអីចឹងហោសបង?
ខ៖ នៅពេលដែរចូលឆ្នាំខ្មែរនឹងបីបួននាក់ពួកម៉ាក់នឹងនាំគ្នាទៅហើយនឹង
ក៖ បាទបងចុះបងចេះច្រៀងទេបង?
ខ៖ អត់សូរចេះទេនឹង
ក៖ ប៉ុន្តែបងចូលចិត្តស្តាប់បទចំរៀងអត់បង?
ខ៖ ចូលចិត្តស្តាប់ដែរនឹង
ក៖ លក្ខណៈជាបទបុរាណ រឺមួយក៏បទបុរាណដែរបង?
ខ៖ ធម្មតានឹងបទបុរាណក៏ចូលចិត្ត បទសម័យក៏ខ្ចុំចូលចិត្តដែរនឹង
ក៖ អ៊ូ!បាទបង ចុះបងមាននរណាគេនៅក្នុងក្រុមគ្រួសាររបស់បង
រឺមួយក៏បងប្អូនជីដូនមួយអីដែរពួកគាត់ ចេះលេងឧបករណ៍ភ្លេងដែរទេបង?
ខ៖ អត់ចេះទេបងអើយ
ក៖ លក្ខណៈអកកណ្តង ភ្លេងពិនពាត ភ្លេងសៀម
ភ្លេងខ្មែរអីក៏បងមិនចេះដែរណាបង?
ខ៖ អត់ទេបងអត់មានទេនឹង
ក៖
ចុះផ្ទះរបស់បងមានលក្ខណៈបែបណាដែរតាំងពីក្មេងរហូតមកដល់ពេលនេះហាស?
ខ៖ ផ្ទះរបស់ខ្ញុំ?

ក៖ ដូចជាពីក្មេងផ្ទះយ៉ាងម៉េច ហើយឥឡូវនឹងផ្ទះយ៉ាងម៉េចដូចជាផ្ទះឈើ
រឺមួយក៏ថ្ម រឺធំតូចអីចឹងហាស បង?
ខ៖ ពីខ្ញុំនៅពីក្មេងផ្ទះរបស់ខ្ញុំនឹងស្លឹកប៉ុននោះទេនឹង
ដល់ពេលដែរកូនធំគិចទៅម៉ែឪចេះតែធ្វើសល់ខ្លះៗៗ
ទៅកាត់ធ្វើបានផ្ទះខ្ពស់ប៉ុននេះទៅណាស
ក៖
ប៉ុន្តែផ្ទះទាំងអស់នឹងដូចជាបងធ្វើដោយខ្លួនឯងរឺមួយក៏បងជួលគេធ្វើដែរបង?
ខ៖ ជួលគេបងជួលគេនឹង
ក៖ អ៎ូ!ប៉ុន្តែបងចេះធ្វើផ្ទះទេបង?
ខ៖ អត់ចេះធ្វើផ្ទះទេបងប៉ុន្តែគ្រាន់តែយើងអាចធ្វើជាកូនជាងគេបាននឹង
យើងអាចរៃដេកគោលអីចឹង ហាស
ក៖ អ៎ូ!បានបង ចុះបងគិតថាជំនាញអីដែរបងចេះស្ទាត់ជំនាញដែរបង?
ខ៖ គ្មានអីស្ទាត់រលីងនឹងមិនចេះអីអោយពិតប្រាកដទេបងអើយ
ក៖ គឺគិតថាលក់ដូរ
រឺមួយក៏ធ្វើជាគ្រឿងសំណង់ដែរបងគិតថាបងចេះតែម្តងនឹងហាស?
ខ៖ រឿងដែរចេះធម្មតាទេបងដើរធ្វើនោះគិច នេះគិចចេះតែធ្វើទៅ
ក៖
ចុះឪពុកម្តាយរបស់បងគាត់មានធ្លាប់បង្រៀនពីជំនាញអីទៅបងទេដូចជាវេញរ
ល្វី កូរស្ករត្នោត ធ្វើផ្តៅអីទេបង?
ខ៖ បញ្ចូលដេកកេះ
ក៖ អ៎ូ!បញ្ចូលដែកកេះហោសបង?
ខ៖ បាទនឹង
ក៖ នឹងបងចេះពីឪពុកម្តាយនឹង?
ខ៖ បាទចេះពីឪពុកនឹង
ក៖ ប៉ុន្តែគាត់ចេះមកពីនរណាគេចឹងដែរបង?
ខ៖ គាត់ចេះពីនរណាគេបង្រៀនគាត់ផ្សេងៗៗដែរនឹង
ក៖ អ៎ូ!បានបង
ចុះបងអាចប្រាប់ខ្ញុំបានទេពីបាលដែរលំបាកបងគិតថាពេលណាដែរបងលំបាក
តាំងពី ក្មេងរហូតមកដល់ពេលនេះហាសបង
ដូចថាពីក្មេងនឹងបងលំបាកអីគេហើយឥឡូវនឹងបងលំបាកអីគេចឹងហាសបង?
ខ៖ ដូចជាធម្មតាបងគ្មានលំបាកអីទេ
លំបាកជាងគេពេលដែរកូនឈឺលំបាកមែនទែនតែម្តងនឹងបង
ពេលដែរកូនឈឺថាបន់ធ្វើម៉េចក៏ដោយអោយតែកូនជាវិញ
ពិបាកៗៗតែម្តងពេលដែរឃើញកូនក្តៅនឹងថា ពិបាកៗៗយកតែមែនទែននឹង
បើអោយនិយាយការពិបាកពេលដែរយើងរកស៊ីនឹងគឺពិបាកធុញថប់តែ
ពេលដែរយើងទៅរកស៊ីនឹងទេដល់ពេលមកដល់ផ្ទះនឹងមានអារម្មណ៍សប្បាយវិញ
ហើយនឹង
ក៖ អ៎ូ!បានបង
ចុះបងកាលពីបងនៅក្មេងៗៗនឹងបងមានធ្លាប់គិតថាបងមានការលំបាកអីគេ
ដែរទេបង?
ខ៖
កាលពីក្មេងៗៗនឹងលំបាកតែពេលដែរម៉ែអោយទៅធ្វើការងារហើយមិនចង់ទៅនឹ
ងនឹងពិបាកតែម្តង នឹងហាស
ក៖ ប៉ុន្តែពេលណាងដូចជាវាអស់សង្គ្រាមអីហើយណាបង?
ខ៖ អស់ហើយនឹង
ក៖ ចឹងលែងមានអីត្រូវភ័យខ្លាចទៀតហើយណាបង?
ខ៖ លែងភ័យហើយនឹងភ័យខ្លាចទៀតនឹង
ក៖ តែគ្រាន់តែពិបាកម៉ែឪរបស់បងអោយទៅធ្វើការ?
ខ៖ បាទនឹងហើយ
ក៖ ចុះបងគិតថានៅពេលដែរបងមានប្រពន្ធ
រឺក៏បងទើបមានប្រពន្ធហើយបងគិតថាបងមានការលំបាក អីទេបង?

ខ៖
ពេលដែរមានប្រពន្ធហើយយើងគិតថាលំបាកមិនដឹងថារកស៊ីអីចិញ្ចឹមគេប្រាក់ខែដើរធ្វើការបុណ្ណឹង ធ្វើការចិញ្ចឹមគេម៉េចរស់ទៅ
ក៖ បាទបងនេះជាការលំបាករបស់បងណបង?
ខ៖ បាទៗនឹងហើយ
ក៖ ចុះបងគិតថាបងឆ្លងកាត់ការលំបាកមួយនឹងដោយរបៀបណាដែរបង?
ខ៖ ចេះតែធ្វើធ្វើទៅបងអើយចេះតែរកការងារធ្វើទៅ
ចេះតែបានប៉ុណ្ណឹងមករហូតនឹង
ក៖ អ៎!បាទ
ចុះបងគិតថាពេលណាដែរបងគិតថាជាពេលដែរសប្បាយនៅក្នុងឆាកជីវិតរបស់បងដែរនឹង បង?
ខ៖ សប្បាយជាងគេនៅពេលដែរជួបជុំបងប្អូន
នឹងម៉ែឪនឹងកូនចៅនឹងសប្បាយជាងគេតែម្តងនឹង
ក៖ អ៎!បាទបងចុះបងគិតថាពេលដែរបងការនឹងបងសប្បាយទេបង?
ខ៖ ការនឹងកាលណុងខ្ញុំភ័យម៉ែឪចាប់យកនឹងខ្ញុំមិនដឹងថាយ៉ាងម៉េចទេ
ការកាលណុងភ័យៗដែរនឹងហាស
ក៖ អ៎!ចឹងហោសបង?
ខ៖ បើមនុស្សយើងស្រលាញ់គ្នាតែម្តងនឹងការសប្បាយចិត្តណាស់បង
ប៉ុន្តែសំរាប់ប្អូនម៉ែឪចាប់ចូលចឹង ដឹងម៉េច
ក៖
ចុះបងគិតថាតាំងពីក្មេងហាសបងធ្លាប់មានក្តីស្រម៉ៃថាពេលដែរបងធំឡើងនឹងបងចង់ធ្វើអីទេបង?
ខ៖ ពីក្មេងធំឡើងអីនឹងធម្មតានឹងចង់ធ្វើការដូចគេដូចឯងនឹង
ក៖
លក្ខណៈថាកាលពីបងនៅរៀននឹងបងធ្លាប់មានក្តីស្រម៉ៃប្រាប់មិត្តភក្តិថាពេលដែរបងធំឡើងចឹងបង ចង់ធ្វើគ្រូពេទ្យ រឺគ្រូបង្រៀន រឺចង់ធ្វើប៉ូលីសអីចឹងហាស?
ខ៖ ខ្ញុំចង់ធ្វើជាគ្រូបង្រៀននឹង
ក៖ អូចង់ធ្វើជាគ្រូបង្រៀនណបង?
ខ៖ បាទនឹងហើយ
ក៖ ចុះបើសិនជាចង់អោយបងផ្តែផ្តាំទៅអោយពួកគាត់បានស្តាប់ហាស
តើបងចង់ផ្តែផ្តាំអីទៅពួកគាត់ ដែរបង?
ខ៖ ចង់អោយខំប្រឹងរៀននឹងធ្វើមនុស្សល្អគ្រប់ៗគ្នា អោយខំប្រឹងរៀនសូត្រទៅ
ក៖ បាទបាទចឹង?
ខ៖ កុំអោយប្រើប្រាស់គ្រឿងញៀន
ក៖ បាទបងមានអីចង់ផ្តែផ្តាំអីទៀតទេបង?
ខ៖ គ្មានអីចង់ផ្តែផ្តាំទៀតទេបង
ក៖
ចឹងជាចុងក្រោយខ្ញុំអរគុណច្រើនបងដែរបានអោយខ្ញុំសំភាសន៍ពីប្រវត្តិរបស់បង
ហើយការសំភាសន៍ មួយនឹង នឹងទុកដំកល់អោយកូនចៅបងបានស្តាប់
នឹងស្គាល់ពីប្រវត្តិរបស់បងដែរចឹងហាសបង បាទចឹងអរគុណច្រើនបង៕៕